01001617

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 11 / 12 / 2014
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

D82/3/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
# OFFICE OF THE CO-INVESTIGATING JUDGES
# BUREAU DES CO-JUGES D'INSTRUCTION

ពី៖ ចៅក្រម Mark B. Harmon
សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អន្តរជាតិ")

ផ្ញើជូន៖ លោក អាង ឧត្តម
លោក Michael Karnavas
សហមេធាវីតំណាងជនសង្ស័យ

កាលបរិច្ឆេទ៖ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤

**សម្ងាត់ ប្តូរទៅជាសាធារណៈ**

កម្មវត្ថុ៖ **សំណើសុំព័ត៌មានទាក់ទងនឹងកំណត់ហេតុនៃករណីខ្វែងយោបល់គ្នាចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣**[1]

១. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានទទួលលិខិតមួយពីសហមេធាវីតំណាងជនសង្ស័យ មាស មុត ("មេធាវីជនសង្ស័យ") ដែលស្នើសុំព័ត៌មានអំពីលក្ខណៈទូទៅនៃករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះហត្ថលេខានៅថ្ងៃទី ៧ និងថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("ករណីខ្វែងយោបល់គ្នា") ដែលបានលើកយោងនៅក្នុង *ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត(D82)* និង

[1]សំណុំរឿង ០០៣ ឯកសារ D82/3/1 *សំណើសុំព័ត៌មានទាក់ទងនឹងកំណត់ហេតុនៃករណីខ្វែងយោបល់គ្នាចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣* ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ក្រុងភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

*សុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងសម្ភារៈគាំទ្រ (D82/2)* ("ការជូនដំណឹង")[2]។ មេធាវីជនសង្ស័យបានសួរផងដែរថាតើ ករណីខ្វែងយោបល់គ្នាទាំងនោះ បច្ចុប្បន្ននេះនៅចំពោះមុខ អង្គបុរេជំនុំជម្រះ ឬអត់។

២. ករណីខ្វែងយោបល់គ្នាទាំងអស់ គឺជាឯកសារសម្ងាត់បំផុត លើកលែងតែបញ្ហានានាដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៧២(៤)(ខ)។ អាស្រ័យហេតុនេះ ស.ច.ស.អន្តរជាតិ មិនស្ថិតនៅក្នុងតួនាទីមួយដែលត្រូវជូនដំណឹងលោក អំពីខ្លឹមសារ ឬលក្ខណៈទូទៅនៃករណីខ្វែងយោបល់គ្នាទាំងនោះទេ។ ការលើកយោងករណីខ្វែងយោបល់គ្នាបែបនោះនៅក្នុងសេចក្ដីសម្រេចនានារបស់ ក.ស.ច.ស គឺសុទ្ធតែជាការលើកយោងជាផ្លូវការដែលមានហត្ថលេខារបស់ចៅក្រមតែម្នាក់ប៉ុណ្ណោះ ហើយធ្វើឡើងក្នុងគោលបំណងដើម្បីបង្ហាញការគោរពតាមវេលាពាក់ព័ន្ធ។

៣. ជាការជូនដំណឹងលោក ករណីខ្វែងយោបល់គ្នាទាំងនោះ មិនទាន់បានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះទេ ហើយពេលវេលាសម្រាប់ការដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង ៧២(២) បានផុតកំណត់ហើយ។

---

[2]សំណុំរឿង០០៣ ឯកសារ D82/3 *ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត (D82) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងសម្ភារៈគាំទ្រ (D82/2)* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ (ដាក់នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤)។